**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ក្នុងគោលបំណងសម្រួលនិងគ្រប់គ្រងការតភ្ជាប់បណ្តាញអ៊ីនធឺណិត ដើម្បីពង្រឹងប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃការកៀរគរចំណូលជាតិ ការការពារសន្តិសុខជាតិ និងការថែរក្សារបៀបរៀបរយសណ្តាប់ធ្នាប់សង្គម វប្បធម៌ និងប្រពៃណីជាតិ។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះរាល់ប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញនិងប្រតិបត្តិការសេវាអ៊ីនធឺណិតនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រម ដែលជាឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ។

## ជំពូកទី២
## ការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ
### ផ្នែកទី១
### ច្រកទ្វារអ៊ីនធឺណិតជាតិ

**មាត្រា៤ .-**

ត្រូវបានបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ដើម្បីសម្រួលនិងគ្រប់គ្រងការតភ្ជាប់បណ្តាញអ៊ីនធឺណិតក្នុងប្រទេស និងអន្តរជាតិ។

ច្រកទ្វារអ៊ីនធឺណិតជាតិរួមមាន ច្រកទ្វារអ៊ីនធឺណិតក្នុងប្រទេស សម្រាប់ផ្លាស់ប្តូរទិន្នន័យអ៊ីនធឺណិតក្នុងប្រទេស និងច្រកទ្វារអ៊ីនធឺណិតអន្តរជាតិ សម្រាប់ផ្លាស់ប្តូរទិន្នន័យអ៊ីនធឺណិតក្នុងប្រទេសនិងអន្តរជាតិ។

ច្រកទ្វារអ៊ីនធឺណិតក្នុងប្រទេស និងច្រកទ្វារអ៊ីនធឺណិតអន្តរជាតិ នៃច្រកទ្វារអ៊ីនធឺណិតជាតិ ត្រូវធ្វើប្រតិបត្តិការនៅរាជធានីភ្នំពេញ ខេត្តព្រះសីហនុ ក្រុងប៉ោយប៉ែតនៃខេត្តបន្ទាយមានជ័យ និងក្រុងបាវិតនៃខេត្តស្វាយរៀង និងនៅទីតាំងមួយចំនួនទៀតស្របតាមតម្រូវការជាក់ស្តែង ដោយមានការឯកភាពពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សរសេរកាត់ថា**ក.ប.ទ.**។

### ផ្នែកទី២
### ប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិ

**មាត្រា៥ .-**

ច្រកទ្វារអ៊ីនធឺណិតជាតិ ត្រូវធ្វើប្រតិបត្តិការដោយប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិ ដែលត្រូវកំណត់ដោយការសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រី**ក.ប.ទ.**។

បុគ្គលដែលមានបំណងធ្វើប្រតិបត្តិការច្រកទ្វារអ៊ីនធឺណិតជាតិ ត្រូវដាក់ពាក្យសុំអាជ្ញាបណ្ណពីនិយ័តករទូរគមនាគមន៍កម្ពុជា សរសេរកាត់ថា**ន.ទ.ក.**។ លក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំ ផ្តល់ ព្យួរ និងដកហូតអាជ្ញាបណ្ណ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី**ក.ប.ទ.**។

**មាត្រា៦ .-**

ប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- គ្រប់គ្រងនិងបង្កលទ្ធភាពងាយស្រួលក្នុងការតភ្ជាប់និងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញនិងសេវាអ៊ីនធឺណិតនៅគ្រប់ច្រកទ្វារអ៊ីនធឺណិតជាតិ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណិតឆ្លងកាត់ព្រំដែនគោក
- រៀបចំបំពាក់អង្គបែងចែកផ្លូវ បមាណី និងគ្រឿងសម្ភារៈបរិក្ខារពាក់ព័ន្ធ ដើម្បីធានាគុណភាព និងសុវត្ថិភាពនៃការតភ្ជាប់បណ្តាញ
- តភ្ជាប់និង/ឬកៀវរីង ជាមួយប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិនិងអន្តរជាតិផ្សេងទៀត
- ផ្តល់របាយការណ៍អំពីស្ថានភាព គុណភាព និងត្រាហ្វិកនៃការតភ្ជាប់បណ្តាញជូន**ក.ប.ទ.**និង**ន.ទ.ក.**
- សហការជាមួយ**ក.ប.ទ. ន.ទ.ក.** និងក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធក្នុងកិច្ចការកៀរគរចំណូលពីការធ្វើពាណិជ្ជកម្មអេឡិចត្រូនិកនិងសេវាកម្មអនឡាញពាក់ព័ន្ធផ្សេងទៀត
- សហការជាមួយ**ក.ប.ទ. ន.ទ.ក.** និងក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត ក្នុងការចាត់វិធានការទប់ស្កាត់និងកាត់ផ្តាច់ចោលរាល់ការតភ្ជាប់បណ្តាញទាំងឡាយដែលប៉ះពាល់ដល់ចំណូលជាតិ សុវត្ថិភាព របៀបរៀបរយសណ្តាប់ធ្នាប់សង្គម សីលធម៌ វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់
- អនុវត្តតួនាទីនិងភារកិច្ចផ្សេងទៀតតាមការណែនាំរបស់រដ្ឋមន្ត្រី**ក.ប.ទ.**។

## ជំពូកទី៣
## ភាតព្វកិច្ចនៃការតភ្ជាប់បណ្ដាញនៃច្រកទ្វារអ៊ីនធឺណិតជាតិ
## ផ្នែកទី១
## បណ្ដាញអ៊ីនធឺណិតក្នុងប្រទេស

**មាត្រា៧ .-**

ក្រៅពីកាតព្វកិច្ចមានចែងក្នុងច្បាប់ស្ដីពីទូរគមនាគមន៍ ប្រតិបត្តិករផ្ដល់សេវាអ៊ីនធឺណិតនិងបុគ្គលពាក់ព័ន្ធ ត្រូវតភ្ជាប់និង/ឬភៀវឹងបណ្ដាញរបស់ខ្លួនជាមួយច្រកទ្វារអ៊ីនធឺណិតក្នុងប្រទេស ដែលស្ថិតក្រោមការគ្រប់គ្រងនិងប្រតិបត្តិការដោយប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិ។

ការតភ្ជាប់និង/ឬភៀវឹងបណ្ដាញរបស់ប្រតិបត្តិករផ្ដល់សេវាអ៊ីនធឺណិតនិងបុគ្គលពាក់ព័ន្ធនេះ ត្រូវអនុវត្តសម្រាប់ការផ្លាស់ប្ដូរត្រាហ្វិកក្នុងប្រទេស តាមរយៈច្រកទ្វារអ៊ីនធឺណិតក្នុងប្រទេស និងអាចទទួលយកការតភ្ជាប់អាយភីអិលស៊ីពីក្រៅប្រទេសតាមរយៈច្រកទ្វារអ៊ីនធឺណិតអន្តរជាតិ។

គំនូសតាងនៃការតភ្ជាប់បណ្ដាញអ៊ីនធឺណិតក្នុងប្រទេសនៃច្រកទ្វារអ៊ីនធឺណិតជាតិ ជាឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

## ផ្នែកទី២
## បណ្ដាញអ៊ីនធឺណិតអន្តរជាតិ

**មាត្រា៨ .-**

ប្រតិបត្តិករដែលបានទទួលអាជ្ញាបណ្ណធ្វើប្រតិបត្តិការច្រកទ្វារទូរគមនាគមន៍អន្តរជាតិ ប្រតិបត្តិការស្ថានីយឡើងគោកនៃខ្សែកាបអុបទិកក្រោមបាតសមុទ្រឬប្រតិបត្តិការបណ្ដាញស្ថានីយផ្កាយរណបលើដីដែលផ្ដល់សេវានៅព្រះរាជាណាចក្រកម្ពុជា ត្រូវតភ្ជាប់បណ្ដាញរបស់ខ្លួនឆ្លងកាត់តាមច្រកទ្វារអ៊ីនធឺណិតជាតិ។

គំនូសតាងនៃការតភ្ជាប់បណ្ដាញអ៊ីនធឺណិតអន្តរជាតិនៃច្រកទ្វារអ៊ីនធឺណិតជាតិ ជាឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

## ផ្នែកទី៣
## ការប្រើប្រាស់លេខប្រព័ន្ធស្វ័យភាពនិងអាសយដ្ឋានអាយភី

**មាត្រា៩ .-**

ប្រតិបត្តិករទូរគមនាគមន៍និងបុគ្គលពាក់ព័ន្ធ ត្រូវប្រើប្រាស់លេខប្រព័ន្ធស្វ័យភាព ភៀវឹងបណ្ដាញអ៊ីនធឺណិតនៅព្រះរាជាណាចក្រកម្ពុជា។

លក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំលេខប្រព័ន្ធស្វ័យភាពនិងអាសយដ្ឋានអាយភី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី**ក.ប.ទ.**។

## ជំពូកទី៤
## គុណភាពសេវា

**មាត្រា១០ .-**

ប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិនិងប្រតិបត្តិករដែលផ្ដល់សេវាទូរគមនាគមន៍គ្រប់ប្រភេទ ត្រូវអនុវត្តតាមលក្ខខណ្ឌនិងស្តង់ដាបច្ចេកទេសនៃការតភ្ជាប់បណ្ដាញនិងការផ្លាស់ប្ដូរត្រាហ្វិកអ៊ីនធឺណិត ស្របតាមប្រកាសរបស់រដ្ឋមន្ត្រី**ក.ប.ទ.**។

ប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិ ត្រូវបំពាក់គ្រឿងសម្ភារៈបរិក្ខារស្នូលនិងបម្រុងសម្រាប់ដំណើរការតភ្ជាប់ និងផ្លាស់ប្តូរត្រាហ្វិកអ៊ីនធឺណិត ដើម្បីធានាសុវត្ថិភាព សុក្រឹតភាព និងគុណភាពដូចខាងក្រោម៖

- ភាពអាចដំណើរការបានដោយគ្មានការរំខានឬការរអាក់រអួល
- កម្រិតប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារនិងបណ្តាញមិនត្រូវលើសពី៨០(ប៉ែតសិប)ភាគរយនៃលទ្ធភាពសរុបនៃគ្រឿងសម្ភារៈបរិក្ខារនិងបណ្តាញ
- ត្រូវមានផែនការថែទាំគ្រឿងសម្ភារៈបរិក្ខារនិងបណ្តាញ។

## ជំពូកទី៥
## កម្រៃតភ្ជាប់បណ្តាញ

**មាត្រា១១ .-**

ថ្លៃប្រើប្រាស់នៃចំណុចប្រសព្វនិងកម្រៃផ្សេងទៀត ដើម្បីដំណើរការតភ្ជាប់បណ្តាញអ៊ីនធឺណិតក្នុងទម្រង់ឆ្លងកាត់ឬកៀរវីងនៅច្រកទ្វារអ៊ីនធឺណិតជាតិ ត្រូវគិតទៅតាមចំនួន ប្រភេទ និងចំណុះល្បឿននៃចំណុចប្រសព្វ ដែលត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រី**ក.ប.ទ.** និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៦
## កិច្ចការកៀរគរចំណូល ការពារសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ

**មាត្រា១២ .-**

ប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិ ត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីកៀរគរចំណូលជាតិ ធានាសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ សីលធម៌ វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់សង្គម ព្រមទាំងបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសនានា។ ចំពោះយន្តការនៃកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាង**ក.ប.ទ.**និងក្រសួងស្ថាប័នដែលមានសមត្ថកិច្ច។

ប្រតិបត្តិករផ្តល់សេវាទូរគមនាគមន៍គ្រប់ប្រភេទដែលតភ្ជាប់ជាមួយប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិ ត្រូវតម្រូវឱ្យអ្នកប្រើប្រាស់បណ្តាញសេវាទូរគមនាគមន៍គ្រប់ប្រភេទបំពេញបែបបទនិងមានអត្តសញ្ញាណសម្គាល់ត្រឹមត្រូវស្របតាមបទប្បញ្ញត្តិជាធរមាន។

**ក.ប.ទ.**និងក្រសួងស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវសហការបង្ក្រាបអំពើល្មើសទាក់ទងនឹងការតភ្ជាប់ និងប្រើប្រាស់បណ្តាញអ៊ីនធឺណិតឆ្លងដែនខុសច្បាប់។

## ជំពូកទី៧
## របាយការណ៍និងការត្រួតពិនិត្យ

**មាត្រា១៣ .-**

ប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិ ត្រូវផ្តល់របាយការណ៍ត្រាហ្វិកជូន**ក.ប.ទ.**និង**ន.ទ.ក.** ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ក្នុងរយៈពេល៧(ប្រាំពីរ)ថ្ងៃ ក្រោយដំណាច់ខែ ត្រីមាស ឆមាស នព្វមាស និងឆ្នាំនីមួយៗ។

ក្នុងករណីដែលមានការកកស្ទះត្រាហ្វិកអ៊ីនធឺណិត ប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិ ត្រូវធ្វើរបាយការណ៍ជូន**ក.ប.ទ.**និង**ន.ទ.ក.** អំពីស្ថានភាពតភ្ជាប់ទៅតាមទិសដៅឬចំណុចដែលកកស្ទះ ដោយបញ្ជាក់ពីមូលហេតុ និងលើកជាដំណោះស្រាយឱ្យទាន់ពេលវេលា។

**មាត្រា១៤ ._**

**គ.ប.ទ.**និង**ន.ទ.គ.** មានសិទ្ធិត្រួតពិនិត្យលើហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញនិងគ្រឿងសម្ភារៈបរិក្ខារនៃច្រកទ្វារអ៊ីនធឺណិតជាតិ ក្នុងករណីចាំបាច់។

ប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិ ត្រូវ៖

- រៀបចំនិងថែរក្សាកំណត់ត្រាបច្ចេកទេសនិងតារាងបែងចែកការផ្តល់អាសយដ្ឋានអាយភីនិងការកំណត់ផ្លូវនៃត្រាហ្វិកឆ្លងកាត់នៅច្រកទ្វារអ៊ីនធឺណិតជាតិ
- ចងក្រងនិងរក្សាទុករបាយការណ៍និងឯកសារពាក់ព័ន្ធនឹងលក្ខណៈតភ្ជាប់ និងត្រាហ្វិកប្រើប្រាស់នៃសេវាអ៊ីនធឺណិតគ្រប់ប្រភេទ
- ផ្តល់ព័ត៌មានផ្សេងទៀត ស្របតាមការតម្រូវរបស់**គ.ប.ទ.**និង**ន.ទ.គ.**។

ប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិ ត្រូវរក្សាទុកកំណត់ត្រាបច្ចេកទេសនិងតារាងបែងចែកការផ្តល់អាសយដ្ឋានអាយភីនិងការកំណត់ផ្លូវនៃត្រាហ្វិកឆ្លងកាត់នៅច្រកទ្វារអ៊ីនធឺណិតជាតិសម្រាប់រយៈពេល១២(ដប់ពីរ)ខែចុងក្រោយ។

## ជំពូកទី៨
## បណ្តឹងតវ៉ា

**មាត្រា១៥ ._**

បុគ្គលណាដែលមិនសុខចិត្តចំពោះវិធានការណាមួយនៃទណ្ឌកម្មនៅក្នុងអនុក្រឹត្យនេះ អាចប្តឹងតវ៉ាក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ទៅ**គ.ប.ទ.** គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច។ រដ្ឋមន្ត្រី**គ.ប.ទ.** ត្រូវសម្រេចលើបណ្តឹងតវ៉ានេះក្នុងរយៈពេល៤៥(សែសិបប្រាំ)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបណ្តឹង។

ក្នុងករណីបុគ្គលនោះមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រី**គ.ប.ទ.** បុគ្គលនោះមានសិទ្ធិធ្វើបណ្តឹងទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេចរបស់រដ្ឋមន្ត្រី**គ.ប.ទ.**។

បណ្តឹងរបស់បុគ្គលដែលទទួលរងនូវវិធានការណាមួយនៃទណ្ឌកម្មនៅក្នុងអនុក្រឹត្យនេះទៅតុលាការ ពុំមានអានុភាពផ្អាកការអនុវត្តសេចក្តីសម្រេចរបស់រដ្ឋមន្ត្រី**គ.ប.ទ.** ឡើយ។

## ជំពូកទី៩
## ទណ្ឌកម្ម

**មាត្រា១៦ ._**

ក្នុងករណីពិនិត្យឃើញថា ប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិ មិនអនុវត្តតាមកាតព្វកិច្ចណាមួយ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិនៃមាត្រា៦និងមាត្រា១២នៃអនុក្រឹត្យនេះ **ន.ទ.គ.**អាចដឹកនាំកែតម្រូវ។ ក្នុងករណីប្រតិបត្តិករមិនបានធ្វើការកែតម្រូវតាមការណែនាំរបស់**ន.ទ.គ.** **ន.ទ.គ.**អាចចាត់វិធានការមួយឬច្រើនដូចខាងក្រោម៖

ក. ដាក់កំហិតលើអាជ្ញាបណ្ណ។

ខ. ព្យួរអាជ្ញាបណ្ណ។

គ. ជ្រើសរើសនិងផ្តល់អំណាចដល់បុគ្គលដែលមានសមត្ថកិច្ចសមស្រប ដើម្បីពិនិត្យមើលសកម្មភាពអាជីវកម្មឬសកម្មភាពពាក់ព័ន្ធផ្សេងទៀតរបស់ប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិ។ បុគ្គលនោះត្រូវធ្វើរបាយការណ៍ឱ្យទៅ**ន.ទ.គ.** តាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យាជាមួយ**ន.ទ.គ.**។

ឃ. ដកអាជ្ញាបណ្ណ។

ង. ស្នើសុំបង្កកគណនីដោយអនុវត្តស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ច. ពិន័យអន្តរការណ៍ ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ក្នុងវិស័យទូរគមនាគមន៍ បន្ថែមលើវិធានការណាមួយដូចមានចែងក្នុងចំណុចក ខ គ ឃ និងង នៃមាត្រានេះ។

ឆ. ចាត់វិធានការផ្សេងទៀតតាមការចាំបាច់ ស្របតាមការកំណត់ដោយច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**មាត្រា១៧ .-**

ក្នុងករណីពិនិត្យឃើញថា ប្រតិបត្តិករផ្តល់សេវាអ៊ីនធឺណិត ប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធដែលមិនអនុវត្តតាមកាតព្វកិច្ចណាមួយ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិនៃមាត្រា៧ មាត្រា៨ និងមាត្រា៩នៃអនុក្រឹត្យនេះ **ន.ទ.ក.**អាចដឹកនាំកែតម្រូវ។ ក្នុងករណីប្រតិបត្តិករមិនបានធ្វើការកែតម្រូវតាមការណែនាំរបស់**ន.ទ.ក.** **ន.ទ.ក.** អាចចាត់វិធានការមួយឬច្រើនដូចខាងក្រោម៖

ក. ដាក់កំហិតលើអាជ្ញាបណ្ណ។

ខ. ព្យួរអាជ្ញាបណ្ណ។

គ. ដកអាជ្ញាបណ្ណ។

ឃ. ស្នើសុំបង្កកគណនីដោយអនុវត្តស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ង. ពិន័យអន្តរការណ៍ ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ក្នុងវិស័យទូរគមនាគមន៍ បន្ថែម លើវិធានការណាមួយដូចមានចែងក្នុងចំណុចក ខ គ និងឃ នៃមាត្រានេះ។

ច. ចាត់វិធានការផ្សេងទៀតតាមការចាំបាច់ ស្របតាមការកំណត់ដោយច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

## ជំពូកទី១០
## អន្តរប្បញ្ញត្តិ

**មាត្រា១៨ .-**

រាល់ការអនុញ្ញាតលើការតភ្ជាប់បណ្តាញរូបវន្តឆ្លងកាត់ព្រំដែនមុនពេលអនុក្រឹត្យនេះចូលជាធរមាន ត្រូវចាត់ទុកជានិរាករណ៍ក្នុងរយៈពេល១២(ដប់ពីរ)ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន លើកលែងតែសិទ្ធិដែលត្រូវបានផ្តល់ក្រោមអាជ្ញាបណ្ណប្រតិបត្តិការច្រកទ្វារទូរគមនាគមន៍អន្តរជាតិនិងអាជ្ញាបណ្ណប្រតិបត្តិការស្ថានីយឡើងគោកនៃខ្សែកាបអុបទិកក្រោមបាតសមុទ្រ។

ប្រតិបត្តិករដែលបានទទួលអាជ្ញាបណ្ណច្រកទ្វារទូរគមនាគមន៍អន្តរជាតិនិងអាជ្ញាបណ្ណប្រតិបត្តិការស្ថានីយឡើងគោកនៃខ្សែកាបអុបទិកក្រោមបាតសមុទ្រ និងប្រតិបត្តិករផ្តល់សេវាអ៊ីនធឺណិត ដែលកំពុងតភ្ជាប់បណ្តាញនិងលក់ដុំសេវាអ៊ីនធឺណិតដោយផ្ទាល់ ត្រូវបង្វែរមកឆ្លងកាត់ច្រកទ្វារអ៊ីនធឺណិតជាតិឱ្យបានជាស្ថាពរក្នុងរយៈពេល១២(ដប់ពីរ)ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។

ប្រតិបត្តិករផ្តល់សេវាអ៊ីនធឺណិតនិងបុគ្គលពាក់ព័ន្ធត្រូវតភ្ជាប់និង/ឬរៀបចំបណ្តាញរបស់ខ្លួនទៅច្រកទ្វារអ៊ីនធឺណិតជាតិឱ្យបានជាស្ថាពរក្នុងរយៈពេល១២(ដប់ពីរ)ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។

## ជំពូកទី១១
## អវសានប្បញ្ញត្តិ

**មាត្រា១៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៥ កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០២១

## ស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ

## សន្ទានុក្រមសម្រាប់ប្រើប្រាស់ក្នុងអនុក្រឹត្យនេះ

| | |
|---|---|
| **ច្រកទ្វារអ៊ីនធឺណិតក្នុងប្រទេស**<br>Domestic Internet Exchange - DIX | សំដៅដល់ច្រកទ្វារអ៊ីនធឺណិតដែលប្រតិបត្តិករក្នុងស្រុកអាចផ្លាស់ប្តូរទិន្នន័យរវាងគ្នាដោយពុំចាំបាច់ឆ្លងតាមបណ្តាញក្នុងប្រទេសដទៃ។ |
| **ច្រកទ្វារអ៊ីនធឺណិតអន្តរជាតិ**<br>International Internet Gateway - IIG | សំដៅដល់ច្រកទ្វារអ៊ីនធឺណិតអន្តរជាតិដែលផ្លាស់ប្តូរទិន្នន័យរវាងបណ្តាញអ៊ីនធឺណិតក្នុងស្រុកនៃប្រទេសមួយនិងប្រទេសមួយទៀត។ |
| **ច្រកទ្វារអ៊ីនធឺណិតជាតិ**<br>National Internet Gateway | សំដៅដល់ច្រកទ្វារដែលសេវាអ៊ីនធឺណិតគ្រប់ប្រភេទត្រូវតភ្ជាប់បណ្តាញទៅវិញទៅមកក្នុងប្រទេសនិងអន្តរជាតិ។ ច្រកទ្វារអ៊ីនធឺណិតជាតិរួមមានច្រកទ្វារអ៊ីនធឺណិតក្នុងប្រទេស(DIX) និងច្រកទ្វារអ៊ីនធឺណិតអន្តរជាតិ(IIG)។ |
| **ត្រាហ្វិក**<br>Traffic | សំដៅដល់បរិមាណនៃទិន្នន័យដែលឆ្លងកាត់បណ្តាញនៅក្នុងរយៈពេល ១(មួយ)វិនាទី នៃខណៈពេលជាក់លាក់មួយ។ |
| **បុគ្គលពាក់ព័ន្ធ**<br>Concerning Person | សំដៅដល់ប្រតិបត្តិករផ្តល់សេវាទូរគមនាគមន៍ បុគ្គលផ្តល់សេវាមាតិកា មជ្ឈមណ្ឌលទិន្នន័យ សមាគម និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដែលត្រូវតភ្ជាប់និងផ្លាស់ប្តូរទិន្នន័យរវាងគ្នាតាមរយៈច្រកទ្វារអ៊ីនធឺណិតក្នុងប្រទេសទោះដោយផ្ទាល់ឬប្រយោល។ |
| **ប្រតិបត្តិករផ្តល់សេវាអ៊ីនធឺណិត**<br>Internet Service Provider - ISP | សំដៅដល់ប្រតិបត្តិករផ្តល់សេវាអ៊ីនធឺណិតជូនអតិថិជន។ |
| **បមាណី**<br>Switch | សំដៅដល់ឧបករណ៍បណ្តាញមួយប្រភេទ ដែលអនុញ្ញាតឱ្យឧបករណ៍ចុងក្រោយនៃបណ្តាញជាមួយគ្នាឬផ្សេងគ្នាអាចផ្លាស់ប្តូរទិន្នន័យរវាងគ្នាបានតាមរយៈពិធីសារត្រឹមស្រទាប់ទី២ (Data Link Layer)។ |
| **ភៀរីង**<br>Peering | សំដៅដល់ការផ្លាស់ប្តូរទិន្នន័យដោយផ្ទាល់រវាងបណ្តាញរបស់ប្រតិបត្តិករផ្តល់សេវាអ៊ីនធឺណិតនិងបុគ្គលពាក់ព័ន្ធ ជាជាងឆ្លងកាត់តាមបណ្តាញអ៊ីនធឺណិត។ |
| **មជ្ឈមណ្ឌលទិន្នន័យ**<br>Data Center | សំដៅដល់ទីតាំងដែលផ្តល់សេវារក្សាទុក ដំណើរការវិភាគ ការពារសុវត្ថិភាពបញ្ជូនទទួលទិន្នន័យ និងសេវាពាក់ព័ន្ធ។ |
| **មាតិកា**<br>Content | សំដៅដល់កម្រងព័ត៌មានដែលត្រូវបានរក្សាទុក ដំណើរការ ឬផ្សព្វផ្សាយក្នុងទម្រង់ឌីជីថល តាមរយៈកុំព្យូទ័រ កុំព្យូទ័របន្ទះ ទូរសព្ទឆ្លាត ឬឧបករណ៍បច្ចេកវិទ្យាផ្សេងៗទៀត។ |
| **លេខប្រព័ន្ធស្វ័យភាព**<br>Autonomous System Number - ASN | សំដៅដល់ក្រុមបុព្វបទអាយភី ដែលលេខសម្គាល់អត្តសញ្ញាណមានតែមួយគត់សម្រាប់ប្រព័ន្ធស្វ័យភាពមួយនិងមានសម្រាប់ការប្រើប្រាស់នៅទូទាំងពិភពលោក ដើម្បីឱ្យប្រព័ន្ធស្វ័យភាពអាចផ្លាស់ប្តូរព័ត៌មាននាំផ្លូវជាមួយនឹងប្រព័ន្ធស្វ័យភាពផ្សេងទៀត។ ដើម្បីឱ្យប្រព័ន្ធស្វ័យភាព |

អាចទាក់ទងគ្នាបានលើបណ្ដាញអ៊ីនធឺណិត ប្រព័ន្ធនេះត្រូវការលេខប្រព័ន្ធស្វ័យភាពសាធារណៈ (Public ASN)។

**អង្គបែងចែកផ្លូវ**
Router

សំដៅដល់ឧបករណ៍បណ្ដាញមួយប្រភេទ ដែលអនុញ្ញាតឱ្យឧបករណ៍ចុងក្រោយនៃបណ្ដាញជាមួយគ្នាឬផ្សេងគ្នាអាចផ្លាស់ប្ដូរទិន្នន័យរវាងគ្នាបានតាមរយៈពិធីសារត្រឹមស្រទាប់ទី៣ (Network Layer)។

**អ៊ីនធឺណិត**
Internet

សំដៅដល់បណ្ដាញកុំព្យូទ័រពិភពលោកដែលអាចឱ្យមនុស្សចែករំលែកព័ត៌មាននិងទាក់ទងគ្នាទៅវិញទៅមក។

**អាយភីត្រង់ស៊ីត**
IP Transit

សំដៅដល់សេវាលក់ដុំមួយប្រភេទ ដែលប្រតិបត្តិករផ្តល់សេវាអ៊ីនធឺណិតអនុញ្ញាតឱ្យត្រាហ្វិកដទៃឆ្លងកាត់បណ្ដាញរបស់ខ្លួនជាមួយលក្ខខណ្ឌនិងល្បឿនបញ្ជូនទៅកាន់គោលដៅចុងក្រោយ។

**អាយភីអិលស៊ី**
International Private Leased Circuit - IPLC

សំដៅដល់សេវាដែលអនុញ្ញាតឱ្យមានការជួលបណ្ដាញជាលក្ខណៈឯកជនពីចំណុចមួយទៅចំណុចមួយទៀតនៅទូទាំងពិភពលោក។

**អាសយដ្ឋានអាយភី**
IP Address

សំដៅដល់អាសយដ្ឋានមានទម្រង់ជាលេខសម្រាប់សម្គាល់ឱ្យកុំព្យូទ័រឬឧបករណ៍មួយនៅក្នុងបណ្ដាញឬអ៊ីនធឺណិត។

ឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០២១

## ស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ

## គំនូសតាងនៃការតភ្ជាប់បណ្តាញនៃច្រកទ្វារអ៊ីនធឺណិតជាតិ



(១) : ប្រតិបត្តិករផ្តល់សេវាទូរសព្ទចល័ត ប្រតិបត្តិករផ្តល់សេវាអ៊ីនធឺណិត មជ្ឈមណ្ឌលទិន្នន័យ បុគ្គលផ្តល់សេវាមាតិកា ស្ថាប័ន និងសហគមន៍ផ្សេងទៀត ត្រូវតភ្ជាប់និងភៀរីងបណ្តាញរបស់ខ្លួនជាមួយច្រកទ្វារអ៊ីនធឺណិតក្នុងប្រទេស ដែលស្ថិតក្រោមការគ្រប់គ្រងនិងប្រតិបត្តិការដោយប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិ។

(២) : ប្រតិបត្តិករដែលបានទទួលអាជ្ញាបណ្ណធ្វើប្រតិបត្តិការស្ថានីយឡើងគោកនៃខ្សែកាបអុបទិកក្រោមបាតសមុទ្រ ត្រូវតភ្ជាប់បណ្តាញរបស់ខ្លួនឆ្លងកាត់តាមច្រកទ្វារអ៊ីនធឺណិតអន្តរជាតិ ដែលស្ថិតក្រោមការគ្រប់គ្រងនិងប្រតិបត្តិការដោយប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិ។

(៣) : ប្រតិបត្តិករដែលបានទទួលអាជ្ញាបណ្ណធ្វើប្រតិបត្តិការច្រកទ្វារទូរគមនាគមន៍អន្តរជាតិ ត្រូវតភ្ជាប់បណ្តាញរបស់ខ្លួនឆ្លងកាត់តាមច្រកទ្វារអ៊ីនធឺណិតអន្តរជាតិ ដែលស្ថិតក្រោមការគ្រប់គ្រងនិងប្រតិបត្តិការដោយប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិ។

(៤) : ប្រតិបត្តិករដែលបានទទួលអាជ្ញាបណ្ណធ្វើប្រតិបត្តិការបណ្តាញស្ថានីយផ្កាយរណបលើដីដែលផ្តល់សេវានៅព្រះរាជាណាចក្រកម្ពុជា ត្រូវតភ្ជាប់បណ្តាញរបស់ខ្លួនឆ្លងកាត់តាមច្រកទ្វារអ៊ីនធឺណិតអន្តរជាតិ ដែលស្ថិតក្រោមការគ្រប់គ្រងនិងប្រតិបត្តិការដោយប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិ។